























*Don't Drink and Drive*

# ខេមប្រ៊ូវ មានកិត្តិយសដែលបានក្លាយជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកិច្ចការសាជីវកម្មតំបន់អាស៊ី ឆ្នាំ២០២៣



ក្នុងនាមជាបុត្រសម្ព័ន្ធមួយរបស់ កាសស្បឺរ គ្រុប ខេមប្រ៊ូវ មានក្ដីសោមនស្សជាខ្លាំង ដែលបានក្លាយជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកិច្ចការសាជីវកម្មតំបន់អាស៊ី ឆ្នាំ២០២៣ ដោយ មានការចូលរួមពីសហសេវិកកាសស្បឺរ មកពីទីផ្សារក្នុងតំបន់អាស៊ី រួមមាន ឡាវ វៀតណាម មីយ៉ាន់ម៉ា ម៉ាឡេស៊ី ចិន ឥណ្ឌា ហុងកុង និងថ្នាក់គ្រប់គ្រងផ្នែកកិច្ចសាជីវកម្មមកពី កាសស្បឺរ គ្រុប ទីក្រុង Copenhagen។ កិច្ចប្រជុំនេះ បានប្រព្រឹត្តទៅដោយរលូន រយៈពេល ០៣ថ្ងៃ នៅការិយាល័យកណ្ដាលរបស់ក្រុមហ៊ុន ខេមប្រ៊ូវ រាជធានីភ្នំពេញ។

កិច្ចប្រជុំកិច្ចការសាជីវកម្មតំបន់អាស៊ីឆ្នាំ២០២៣ ជាវេទិកាដែលផ្ដល់ឱកាសដល់សហសេវិកក្នុងផ្នែកកិច្ចការសាជីវកម្ម មកពីទីផ្សារក្នុងតំបន់អាស៊ី និងពីគ្រុប បានជួបជជែកពិភាក្សាគ្នា ផ្ដោតទៅលើគោលបំណង និងលទ្ធភាពដែលអាចអនុវត្តបានសម្រាប់ឆ្នាំខាងមុខ។ វេទិកានេះ ក៏បានអនុញ្ញាតឱ្យពួកគេបានចែករំលែកបទពិសោធន៍ បញ្ហាប្រឈម ដំណោះស្រាយដែលប្រសើរនៅក្នុងទីផ្សាររបស់ខ្លួន ក៏ដូចជាបង្កើតនូវទំនាក់ទំនងជាមួយគ្នាកាន់តែជិតស្និទ្ធ។













ផែនការយុទ្ធសាស្ត្ររយៈពេល ៣ ឆ្នាំ (២០២៣-២០២៥) របស់ផ្នែកកិច្ចការសាជីវកម្ម ក៏បានបង្ហាញ និងចែករំលែកនៅក្នុងកិច្ចប្រជុំរយៈពេលបីថ្ងៃនេះផងដែរ។ ផែនការសកម្មភាពនេះ គឺជាយុទ្ធសាស្ត្រដ៏រឹងមាំមួយ ដែលក្រុមការងារផ្នែកកិច្ចការសាជីវកម្ម មានការឯកភាពគ្នា លើបញ្ហាប្រឈមដែលយើងកំពុងតែជួបប្រទះ និងរិះរកមធ្យោបាយដែលអាចបញ្ចៀសបញ្ហា ទៅថ្ងៃអនាគតប្រកបដោយប្រសិទ្ធភាព ក៏ដូចជាតម្រង់ផ្លូវក្រុមការងារផ្នែកកិច្ចការសាជីវកម្មក្នុងតំបន់អាស៊ី យកទៅអភិវឌ្ឍឱ្យស្របនឹងស្ថានភាពទីផ្សារ រៀងខ្លួន កាន់តែប្រសើរ។

# កិច្ចពិភាក្សាអំពីផែនការសកម្មភាពក្នុងដំណើរឆ្ពោះទៅកាន់គោលដៅចីរភាព«គ្មានសំណល់វេចខ្ចប់»













«គ្មានសំណល់វេចខ្ចប់ ឬ ZERO Packaging Waste» គឺជាមហិច្ឆតាចីរភាពមួយ នៅក្នុង គម្រោងថ្មី ស្តីពី បរិស្ថាន សង្គម និងអភិបាលកិច្ច «រួមគ្នាឆ្ពោះទៅកាន់ហេរ្សូ និងលើសពីនេះ (TTZAB)»។ ដើម្បីចូលរួមចំណែកដល់ការសម្រេចមហិច្ឆតាមួយនេះ ខេមប្រ៊ូវ មានកិត្តិយសបានក្លាយជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលារយៈពេល ០២ថ្ងៃ ស្តីពីកិច្ចពិភាក្សារៀបចំផែនការសកម្មភាពឆ្ពោះទៅកាន់ «គ្មានសំណល់វេចខ្ចប់» សម្រាប់កម្ពុជា និងឡាវ ដោយមានការចូលរួមពីថ្នាក់ដឹកនាំផ្នែកនិរន្តរភាពពីកាសស្បែរ គ្រុប ទីក្រុង Copenhagen និងសហសេវិកផ្នែកខ្សែច្រវាក់ផ្គត់ផ្គង់ និងកិច្ចការសាជីវកម្ម នៃកាសស្បែរ ឡាវ។





សិក្ខាសាលានេះ មានគោលដៅពិភាក្សា ប្រមូលធាតុចូល ដើម្បីបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពដ៏ជាក់លាក់សម្រាប់គោលដៅ «គ្មានសំណល់វេចខ្ចប់» ក៏ដូចជាដើម្បីពិចារណាបន្ថែមទៅលើសកម្មភាពនានា ដែលអាចមានឥទ្ធិពលដល់គោលដៅ និងការគ្រប់គ្រងមហិច្ឆតាចីរភាពរបស់យើង។ សិក្ខាកាម មិនត្រឹមតែបានស្វែងយល់កាន់តែស៊ីជម្រៅអំពីមហិច្ឆតាចីរភាព TTZAB ប៉ុណ្ណោះទេ តែក៏បានចូលរួមផ្តល់ជាគំនិតយោបល់ ដែលជាធាតុចូលយ៉ាងសំខាន់ក្នុងការបង្កើត និងអភិវឌ្ឍផែនការសកម្មភាពសម្រាប់មហិច្ឆតាចីរភាព «គ្មានសំណល់វេចខ្ចប់» របស់យើង ដែលនៅត្រឹមឆ្នាំ ២០៣០ យើងមានមហិច្ឆតាថា សំបកវេចខ្ចប់របស់យើង ១០០ ភាគរយ ត្រូវតែអាចកែច្នៃប្រើប្រាស់ឡើងវិញបាន បង្កើនអត្រាប្រមូលដើម្បីយកទៅកែច្នៃឡើងវិញទាំងសំបកដប និងកំប៉ុង ស្មើនឹង ៩០ ភាគរយ នៃចំនួនសំបកវេចខ្ចប់ដែលយើងប្រើប្រាស់ ប្រើប្រាស់វត្ថុដែលកើតពីការកែច្នៃឡើងវិញ ៥០ ភាគរយនៃចំនួនសំបកវេចខ្ចប់ដែលយើងប្រើប្រាស់ និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកថ្មី (virgin fossil-based plastic) ៥០ ភាគរយ។



ខេមប្រ៊ូវ ជឿជាក់ថា មហិច្ឆតាចីរភាពរបស់យើង រួមគ្នាឆ្ពោះទៅកាន់ហ្សេរ៉ូ ៤ លើសពីនេះ នឹងចូលរួមផ្តល់ដំណោះស្រាយដើម្បីបរិស្ថាន សង្គម និងអភិបាលកិច្ច ដ៏ប្រសើរទាំងថ្ងៃនេះ និងថ្ងៃស្អែក និងធ្វើឲ្យយើងមានអត្តសញ្ញាណខុសប្លែកពីដៃគូប្រកួតប្រជែង។







# ស្រាបៀរ អង្គរ ទទួលបានពិន្ទុខ្ពស់លើភាពឈ្ងុយ និង រសជាតិជាប្រវត្តិសាស្ត្រ តាមរយៈញាណភ្លក់រសជាតិ និងភាពឈ្ងុយ (High Sensory Score)




សូមចូលរួមអបអរសាទរចំពោះប្រវត្តិសាស្ត្រដ៏អស្ចារ្យថ្មី នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ នៃរោងចក្រស្រាបៀររបស់យើង។

រោងចក្ររបស់យើង ទទួលបានពិន្ទុញាណភ្លក់រសជាតិ និងភាពឈ្ងុយ ខ្ពស់ជាប្រវត្តិសាស្ត្រ គឺដល់ទៅ ៦.៨ សម្រាប់ស្រាបៀរអង្គរ និងជាប់ចំណាត់ថ្នាក់លេខ ៣ នៅក្នុងទីផ្សារអាស៊ី។ ការផ្តល់ចំណាត់ថ្នាក់នេះ ធ្វើឡើងនៅក្នុងខែមេសា ឆ្នាំ២០២៣ ដោយអ្នកត្រួតពិនិត្យក្នុងតំបន់ ដែលមានមូលដ្ឋានក្នុងទីក្រុង Qong Qing ប្រទេសចិន។ ក្រុមអ្នកត្រួតពិនិត្យបានផ្តល់ចំណាត់ថ្នាក់លេខ១ ដល់ប្រទេសចិន និងចំណាត់លេខ២ បានទៅប្រទេសមីយ៉ាន់ម៉ា។

*#បន្តរក្សាលទ្ធផលការងារដ៏ប្រសើរនេះ*

CAMBREW LTD
Part of the Carlsberg Group

១៥-មិថុនា-២០២៣ /លេខ៖ CAMMAY2023#7

# ខេមប្រ៊ូវ មានមោទកភាព ដែលបានចូលរួមគាំទ្រក្នុងពិធីធ្វើបទបង្ហាញពីរបាយការណ៍នៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោង «សាងសង់ប្រព័ន្ធចម្រោះទឹកសមុទ្រទៅជាទឹកស្អាត ដំណើរការដោយប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ នៅខេត្តព្រះសីហនុ»




រៀបចំដោយ៖
Organized by:

Desolenator · Carlsberg Group · CAMBREW LTD · CLIMATE FUND MANAGERS · WWF

ជាកិត្តិយស និងក្តីមោទករបស់ ខេមប្រ៊ូវ ដែលបានចូលរួមជាមួយក្រុមហ៊ុន Desolenation កាសស្បឺរ គ្រុប និងដៃគូសំខាន់ៗផ្សេងទៀតរួមមាន Climate Fund Manager , The Dutch Fund for Climate Development, World Wildlife Fund ក្នុងការរៀបចំពិធីធ្វើបទបង្ហាញពីរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគម្រោង«សាងសង់ប្រព័ន្ធចម្រោះទឹកប្រៃទៅជាទឹកស្អាត ដំណើរការដោយប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ក្នុងខេត្តព្រះសីហនុ»។ ពិធីនេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី១០ ខែឧសភា នៅសណ្ឋាគារ សាន់ ៩ មូន រីវើសាយ ភ្នំពេញ។

ដោយមានការអភិវឌ្ឍ និងភាពរីកចម្រើនដ៏ឆាប់រហ័សនៅខេត្តព្រះសីហនុ ដែលមានទាំងការអភិវឌ្ឍកំពង់ផែ តំបន់សេដ្ឋកិច្ចពិសេស គោលដៅទេសចរណ៍ និងអាកាសយានដ្ឋានអន្តរជាតិ យើងត្រូវត្រៀមឲ្យរួចជាស្រេច និងទាន់ពេលវេលានូវការគ្រប់គ្រងធនធានទឹក និងផ្គត់ផ្គង់ទឹកប្រើប្រាស់ ដែលមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ និងកាន់តែមានតម្លៃទៅៗ តាមរយៈដំណោះស្រាយដែលមាននិរន្តរភាព និងប្រកបដោយភាពច្នៃប្រឌិត។ ខេត្តព្រះសីហនុ ត្រូវបានជ្រើសរើសសម្រាប់គម្រោងនេះ ដោយផ្អែកលើការវាយតម្លៃអំពីហានិភ័យទឹកនៅប្រទេសកម្ពុជា ដែលធ្វើឡើងដោយអង្គការ WWF (បានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ ២០២០)។ តាមរយៈការវាយតម្លៃនេះខេត្តព្រះសីហនុ ជាតំបន់ដែលបញ្ហាទឹកប្រើប្រាស់មានហានិភ័យខ្ពស់។ យើងក៏ជឿជាក់ថា គម្រោង សាងសង់ប្រព័ន្ធចម្រោះទឹកប្រៃទៅជាទឹកស្អាត ដំណើរការដោយប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនេះ គឺជាដំណោះស្រាយដ៏មាននិរន្តរភាពមួយ ដែលអាចធានាពីប្រសិទ្ធភាពនៃការគ្រប់គ្រងទឹក និងប្រើប្រាស់ប្រភពទឹកដែលយើងមាន ដោយស័ក្តិសិទ្ធភាព។

កិច្ចសហការរួមគ្នានេះ ក៏ជាសក្ខីភាពមួយបញ្ជាក់ថា នៅពេលយើងរួមគ្នា យើងពិតជាមានសក្តានុពលខ្លាំង ក្នុងការបង្កើតភាពជាគំរូនៃការប្រើប្រាស់ទឹកប្រកបដោយនិរន្តរភាព ដែលជាសកម្មភាពមួយនៃក្តីសង្ឃឹមរបស់ពិភពលោក និងជាការចូលរួមចំណែកដ៏គួរឱ្យកោតស្ញប់ស្ញែង។

ខេមប្រ៊ូវ នឹងព្យាយាមតាមដែលអាចធ្វើបាន ដើម្បីធានាថាសហគមន៍យើង ទទួលបានទឹកស្អាតមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ និងចូលរួមចំណែកធ្វើឱ្យសង្គម និងបរិស្ថានកាន់តែប្រសើរ។

# ខេមប្រ៊ូវ ចូលរួមប្រារព្ធ និងអបអរទិវាអ្នកម្ដាយ ជាមួយប្រជាជនកម្ពុជា និងពិភពលោកទាំងមូល




ដើម្បីប្រារព្ធទិវាអ្នកម្ដាយ និងជាការគោរពដល់ការរួមចំណែក ការខិតខំប្រឹងប្រែង ការលះបង់ និងតួនាទីរបស់អ្នកម្ដាយនៅក្នុងសង្គមរបស់យើង ខេមប្រ៊ូវ បានផលិតខ្សែវីដេអូខ្លីមួយ ដែលឆ្លុះបញ្ចាំងពីគុណម្ដាយមិនអាចប្រៀបបាន ទាំងការចិញ្ចឹមបីបាច់ អប់រំ ដំបូន្មាន ប្រៀនប្រដៅ ក៏ដូចជាពាក្យពេចន៍ក្នុងចិត្តរបស់កូនៗផ្ញើជូនអ្នកម្ដាយនាឱកាសនេះ។

តាមរយៈវីដេអូខ្លីនេះ សហសេវិករបស់យើង បានផ្ញើសារអរគុណអ្នកម្ដាយចំពោះការលះបង់ដើម្បីតែបុគ្គលដែលមានឈ្មោះថា «កូន» ។

វីដេអូនេះ ក៏បានចែករំលែកនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ខេមប្រ៊ូវ៖ Cambrew Ltd ផងដែរ។

អរគុណដល់អ្នកម្ដាយគ្រប់រូប!.

# ខេមប្រ៊ូវ បន្តជំរុញសុចរិតភាពនៅកន្លែងធ្វើការ និងអបអរបុគ្គលិក ២រូប ដែលតែងបង្ហាញភាពស្មោះត្រង់







សូមចូលរួមអបអរសាទរសហសេវិករបស់យើងចំនួន ២រូប ដែលពួកគាត់តែងតែប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងមានក្រមសីលធម៌ខ្ពស់ជាមួយក្រុមការងារ និងត្រូវបានជ្រើសរើសសម្រាប់កម្មវិធីបុគ្គលិកប្រចាំខែលើគុណតម្លៃ «សុចរិតភាព»។

**ប៉ូច ស្រីនិច** អ្នកសម្របសម្រួលផ្នែកជំនួយការលក់ ជាបុគ្គលដែលមានឥរិយាបថគួរឲ្យគោរពរាប់អាន រួសរាយរាក់ទាក់ គោរពពេលវេលា និងមានភាពស្មោះត្រង់ជាមួយក្រុមការងារ។ ជាងនេះទៅទៀត គាត់មានភាពវៃឆ្លាត និងចេះជួយទុក្ខធុរៈក្រុមការងារបានយ៉ាងល្អ។












**ទា សុធារី** អ្នកប្រតិបត្តិរដ្ឋបាលផ្នែកលក់ ជាបុគ្គលដែលឧស្សាហ៍ព្យាយាមនឹងការងារ ច្បាស់លាស់ ហើយតែងតែឲ្យដំបូន្មាន យោបល់ត្រឡប់ដល់ក្រុមការងារពេលត្រួតពិនិត្យឃើញមានកំហុសឆ្គង។ គាត់មានភាពស្មោះត្រង់ ច្បាស់លាស់នឹងការងារ។

ដើម្បីអបអរ និងថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ពួកគាត់ ក្នុងការចូលរួមបង្ហាញយ៉ាងសកម្ម និងលេចធ្លោចំពោះគុណតម្លៃ និងឥរិយាបថ «សុចរិតភាព» យើងបានរៀបចំពិធីប្រគល់ទទួលលិខិតទទួលស្គាល់ និងរង្វាន់លើកទឹកចិត្ត ដោយមានការចូលរួមដោយផ្ទាល់ពីគណៈគ្រប់គ្រងក្រុមហ៊ុន ក៏ដូចជាគណៈកម្មការវាយតម្លៃ។

គុណតម្លៃ និងឥរិយាបថ ជួយគាំទ្រចក្ខុវិស័យរបស់ ខេមប្រ៊ូវ បង្កើតឲ្យមាននូវវប្បធម៌ Triple A ដើម្បីរក្សានូវទំនួលខុសត្រូវរបស់បុគ្គលិក និងបង្ហាញឲ្យឃើញច្បាស់អំពីរបៀបដែល ខេមប្រ៊ូវ និងយើងនៅខេមប្រ៊ូវ គួរតែអនុវត្ត។

# Carlsberg VIP Party រាត្រីជប់លៀងដ៏រំភើប មិនអាចបំភ្លេចបាន




រាត្រីជួបជុំដ៏កក្រើក និងរំភើបរីករាយមិនអាចបំភ្លេចបាន Carlsberg VIP Party ត្រូវបានរៀបចំឡើង ដើម្បីជំរុញពាណិជ្ជសញ្ញាស្រាបៀរ កាសស្បឺរ ឱ្យកាន់តែលេចធ្លោ និងទទួលបានការគាំទ្រពីអតិថិជនបន្ថែមទៀត។ រាត្រីដ៏អស្ចារ្យនេះ ប្រព្រឹត្តទៅកាលពីថ្ងៃទី៥ ខែឧសភា នៅ EDIII club ដោយមានការចូលរួមពីភ្ញៀវកិត្តិយសប្រមាណជាង ៥០០នាក់។

យើងជឿថា ជាមួយនឹងតន្ត្រីដ៏អស្ចារ្យ ព្រមទាំងរសជាតិស្រាបៀរកាសស្បឺរ ដ៏ប្រណីត និងការនាំយកនូវបទពិសោធន៍មិនអាចបំភ្លេចបាន ព្រឹត្តិការណ៍នេះពិតជាបានរួមចំណែកដល់ភាពជោគជ័យរបស់ពាណិជ្ជសញ្ញា កាសស្បឺរ របស់យើង។



# ចែងចាំងដូចមាស ស្រាបៀរ អង្គរ រូបរាងថ្មី កាន់តែទាន់សម័យប្រណីតនិងមោទកភាព







ស្រាបៀរ អង្គរ ដែលជាស្រាបៀរដ៏ពេញនិយមមួយនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យមហាជនភ្ញាក់ផ្អើល និងចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះរូបរាងថ្មី ចែងចាំងដូចមាស ជាមួយនឹងរសជាតិថ្មីស្រស់។

កាលពីពេលថ្មីៗនេះ «ស្រាបៀរ អង្គរ ចែងចាំងដូចមាស» ត្រូវបានសម្ពោធ និងបង្ហាញរូបរាងថ្មីជាផ្លូវការ ជាមួយនឹងរសជាតិថ្មីស្រស់កាន់តែទាន់សម័យ កាន់តែប្រណីត រសជាតិស្រទន់ឆ្ងាញ់ជាប់ចិត្ត ដែលជាជម្រើសដ៏ល្អសម្រាប់អ្នកនិយមស្រាបៀរ និងស័ក្តិសមសម្រាប់ការជួបជុំដ៏រីករាយគ្រប់កម្មវិធី។















ការរចនារូបរាងថ្មីនេះ បានបន្ថែមភាពស្រស់ស្អាត និងគួរឲ្យទាក់ទាញមួយកម្រិតទៀតដល់រូបប្រាង្គប្រាសាទអង្គរវត្តដែលមានស្រាប់ និងរឹតតែបង្ហាញឲ្យឃើញកាន់តែច្បាស់ថា ស្រាបៀរ អង្គរ ជាស្រាបៀររបស់ប្រជាជនខ្មែរ ដែលតែងតែផ្សារភ្ជាប់ជានិច្ចទៅនឹងវប្បធម៌ប្រកបដោយក្តីមោទក ជាមួយនឹងការលើកកម្ពស់កេរដំណែល មរតក និងសម្បត្តិបេតិកភណ្ឌដ៏សម្បូរបែបរបស់កម្ពុជា។ ស្រាបៀរ អង្គរ រូបរាងថ្មី តំណាងឲ្យគុណភាពលំដាប់ខ្ពស់របស់ស្រាបៀរ អង្គរ និងការតម្កល់គុណតម្លៃខ្ពស់ចំពោះមរតកខ្មែរ ដែលជានិមិត្តរូបនៃភាពរីកចម្រើនឥតឈប់ឈរ ភោគទ្រព្យហូរហៀរ និងសុខដុមរមនា។










ពេលនេះ ប្រជាជនខ្មែរដែលនិយមគាំទ្រស្រាបៀរ អាចរីករាយក្រេបឱជារសរបស់ស្រាបៀរ អង្គរ ចែងចាំងដូចមាស រូបរាងថ្មី ដោយក្តីមោទក។

នេះជាសក្ខីភាពមួយចំពោះការខិតខំប្រឹងប្រែងឥតឈប់ឈររបស់ក្រុមហ៊ុន។ ក្នុងការផលិតស្រាបៀរដែលប្រសើរជាងមុន និងភាពមោះមុតមិនផ្លាស់ប្តូរ។ ក្នុងការច្នៃប្រឌិត និងផ្តល់ឲ្យអតិថិជននូវបទពិសោធន៍ថ្មីៗ ភាពសប្បាយរីករាយ និងរសជាតិដ៏ប្រសើរមួយ។

ស្រាបៀរ អង្គរ ត្រូវបានរំពឹងថា នឹងទទួលបានការពេញនិយម និងគាំទ្រកាន់តែខ្លាំងក្លាពីសំណាក់អ្នកនិយមស្រាបៀរ ហើយនឹងអាចពង្រឹងជំហររបស់ខ្លួនឲ្យក្លាយជាពាណិជ្ជសញ្ញាស្រាបៀរដ៏ល្អនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ផងដែរ។

# ភ្លក់រសជាតិដ៏ឆ្ងាញ់ស្រស់ស្រាយ របស់ Somersby ពេលលោកអ្នកកំពុងបង្ហោះខ្លែង










ព្រឹត្តិការណ៍បង្ហោះខ្លែងលំដាប់អន្តរជាតិ SkyFest ២០២៣ ដែលតាមការប៉ាន់ស្មាន មានចំនួនអ្នកចូលរួមជាង ១០,០០០ នាក់។ នេះជាព្រឹត្តិការណ៍ដ៏រីករាយដែលមានសកម្មភាពដ៏រំភើបជាច្រើន បានប្រារព្ធនៅ Bay of Light ក្នុងក្រុងព្រះសីហនុ ដែលជាទីក្រុងឆ្នេរសមុទ្រដ៏ស្អាតបំផុតរបស់កម្ពុជា។

ខ្លែងយក្សអណ្តែតខ្ពស់ពីលើឆ្នេរខ្សាច់ពណ៌សក្បុស តាមលំហូរនៃខ្យល់សមុទ្រ។ Somerbsy មានមោទកភាពដែលចូលរួមក្នុងព្រឹត្តិការណ៍ SkyFest នេះ ដើម្បីបង្កើតបរិយាកាសឱ្យកាន់តែរីករាយថែមទៀត អមដោយការប្រគំតន្ត្រីនាពេលរាត្រីដែលមិនអាចបំភ្លេចបាន និងសកម្មភាពសប្បាយរីករាយជាច្រើន ស្របតាមតម្រូវការរបស់យុវវ័យសម័យថ្មី។

ជាមួយនឹងភាពជោគជ័យនេះ រថយន្តភេសជ្ជៈ Somersby ដែលរចនាឡើងយ៉ាងពិសេស ក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យពុំធ្លាប់មាននេះ បានជំរុញសន្ទុះគាំទ្រពាណិជ្ជសញ្ញា Somersby ពីអតិថិជន។

ក្រោមការគាំទ្រពី ក្រសួងទេសចរណ៍ Somersby ពិតជាមានមោទកភាពដែលបានរួមចំណែកដ៏ស្តួចស្តើង ក្នុងការផ្សព្វផ្សាយតំបន់ទេសចរណដ៏ទាក់ទាញនៃឆ្នេរសមុទ្រខេត្តព្រះសីហនុ ទៅកាន់សាធារណជន នៅក្នុងព្រឹត្តិការណ៍បង្ហោះខ្លែងថ្នាក់អន្តរជាតិ SkyFest ដែលរៀបចំលើកដំបូងបង្អស់នៅកម្ពុជា។








# ការជំរុញ ពិពិធភាព សមធម៌ & បរិយាបន្ន (DE&I) តាមរយៈកម្មវិធី «ស្វាគមន៍អ្នក»




នៅកាសស្ប៊ែរ គ្រុប យើងតែងតែផ្តល់តម្លៃខ្លួនយើងជាមួយនឹងគោលបំណងដ៏ច្បាស់លាស់ ដែលជំរុញគ្រប់សកម្មភាពដែលយើងធ្វើ។

ទស្សនៈ សមត្ថភាព និងបទពិសោធន៍ចម្រុះរបស់ពួកយើង មិនត្រឹមតែជំរុញប្រសិទ្ធភាពការងាររបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏សបញ្ជាក់ពីអត្តសញ្ញាណរបស់យើង នៅទូទាំងគ្រុបផងដែរ។

យើងបានដាក់ចេញនូវកម្មវិធី «ស្វាគមន៍អ្នក៖ ការលើកកម្ពស់ពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I)» ដើម្បីផ្សារភ្ជាប់ DE&I ជាមួយនឹងគោលបំណង ទំនាក់ទំនង ការផ្តួចផ្តើម និងប្រភពផ្សេងៗជុំវិញកាសស្ប៊ែរ គ្រុប។

ជាមួយនឹងពាណិជ្ជសញ្ញាល្បីៗជាច្រើនជុំវិញពិភពលោក យើងដឹងច្បាស់ថា ភាពខុសប្លែកពីគេរបស់យើង គឺជាអ្វីដែលធ្វើឱ្យយើងលេចធ្លោក្នុងកិច្ចការងារនេះ។ ទន្ទឹមនឹងភាពខុសប្លែកពីក្រុមហ៊ុនដទៃ យើងក៏បានរួបរួមគ្នាដោយគោលបំណងរួមមួយរបស់យើងគឺ កាសស្ប៊ែរ រួបរួមជាកម្លាំងដើម្បីរៀងរ៉ាវល្អៗ និងខិតខំប្រឹងប្រែង ដើម្បីអភិវឌ្ឍន៍ឲ្យកាន់តែប្រសើរទាំងថ្ងៃនេះ & ថ្ងៃស្អែក។

រាប់ចាប់ពីស្ថាបនិករបស់យើង J.C. Jacobsen និងស្ថាបនិកពាណិជ្ជសញ្ញាក្នុងស្រុកជាច្រើនទៀតរបស់យើង រហូតដល់សហសេវិកជំនាន់ថ្មីប្រកបដោយភាពចម្រុះចំនួន ៣៨,០០០ នាក់ ទូទាំង កាសស្ប៊ែរ គ្រុប យើងម្នាក់ៗសុទ្ធតែបានរួមចំណែកដល់វប្បធម៌ដ៏សម្បូរបែប និងភាពខុសប្លែកពីគេរបស់យើង។




កម្មវិធី ស្វាគមន៍អ្នក ឬ WELCOME YOU គឺជាការប្តេជ្ញារបស់យើង ក្នុងការអភិវឌ្ឍវប្បធម៌ DE&I នៅគ្រប់ទីកន្លែងដែលយើងមានប្រតិបត្តិការអាជីវកម្ម។

WELCOME YOU គឺជាកម្មវិធីដែលផ្តល់នូវដំណោះស្រាយក្នុងលើកកម្ពស់DE&I ដោយផ្សារភ្ជាប់នូវការសន្ទនាត្រង់ទៅត្រង់មក គួបផ្សំនឹងសកម្មភាពជាក់ស្តែង ព្រមទាំងការបន្តប្តេជ្ញាចិត្ត ដើម្បីធានាតម្លាភាពនៃវឌ្ឍនភាព និងចែករំលែកបទពិសោធន៍របស់យើង។

WELCOME YOU ត្រូវអនុវត្តប្រកបដោយយុត្តិធម៌ សមធម៌ ស្មោះត្រង់ និងទន់ភ្លន់ តាមរយៈការចែករំលែករឿងរ៉ាវផ្សេងៗ ការស្តាប់ និងការចង់ដឹង ចង់ឃើញ។

WELCOME YOU គឺជាអ្វីដែលធ្វើឱ្យ កាសស្បែរ ក្លាយជាទីកន្លែងការងារដែលយើងម្នាក់ៗទទួលបានភាពកក់ក្តៅ និងអាចបង្ហាញចេញនូវសក្តានុពលរបស់យើង ជាកន្លែងដែលយើងរួបរួមកម្លាំងគ្នា ក្នុងការបន្តការប្តេជ្ញាចិត្តរបស់យើង ដើម្បីជំរុញភាពភាពចម្រុះ ភាពស្មើគ្នា និងការទទួលស្គាល់។

CAMBREW LTD

Part of the Carlsberg Group

# រួមគ្នាឆ្ពោះទៅកាន់ហេរ៉ូ

# និងលើសពីនេះ


No. 1881, Russian Boulevard, Phum Ta gnoun, Sangkat Kakab, Khan Posenchey, Phnom Penh, Kingdom of Cambodia

+855 (0) 16 880 695

info.kh@carlsberg.asia

Cambrew Ltd

Cambrewltd

Cambrew Ltd

Carlsberg Group
Carlsberg Cambodia